ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ២៤៥ សខល

ថ្ងៃអង្គារ ១៤រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩**

**ជម្រាបជូន**

**ឯកឧត្តម លោកជំទាវប្រធានគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត**

**កម្មវត្ថុ** ៖ ការធ្វើបច្ចុប្បន្នភាពការព្យាបាលអ្នកជំងឺកូវីដ-១៩ ប្រភេទវិជ្ជមាន (បានបញ្ជាក់ដោយមន្ទីរពិសោធន៍ ឬស្ថិតក្នុងករណីសង្ស័យ) ដើម្បីឆ្លើយតបនឹងការវិវត្តថ្មីនៃសភាពការណ៍នៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងការរស់នៅក្នុងបរិបទថ្មី។

**យោង** ៖

- លិខិតលេខ២៣៩សខល ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១ ស្តីពីការកំណត់លក្ខខណ្ឌក្នុងការបញ្ចប់ការព្យាបាលអ្នកជំងឺកូវីដ-១៩
- ប្រកាសលេខ២៩៦សខល ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យប្រើនីតិវិធីប្រតិបត្តិស្តង់ដារ សម្រាប់គ្រប់គ្រង ថែទាំ និងព្យាបាលអ្នកជំងឺកូវីដ-១៩ នៅតាមផ្ទះ
- របាយការណ៍កិច្ចប្រជុំពិភាក្សាវាយតម្លៃ ការព្យាបាលអ្នកជំងឺកូវីដ-១៩ ប្រភេទវិជ្ជមាន របស់អនុគណៈកម្មការបច្ចេកទេស និងព្យាបាល កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១
- ការចាំបាច់ដើម្បីពង្រឹងការបង្ការ ទប់ស្កាត់ និងគ្រប់គ្រងការឆ្លងរាលដាលវីរុសកូវីដ-១៩ តាមស្ថានភាពវិវត្តន៍បច្ចុប្បន្ននៃជំងឺកូវីដ-១៩ និងការរស់នៅក្នុងបរិបទថ្មី។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកជំទាវប្រធានគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត ជ្រាបថា យោងការសិក្សាវាយតម្លៃលើលទ្ធផលតេស្ត PCR នៃអ្នកជំងឺកូវីដ-១៩ ប្រភេទវិជ្ជមាន ដែលទទួលបានពីមណ្ឌលព្យាបាល និងមន្ទីរពេទ្យព្យាបាលជំងឺកូវីដ-១៩ ចំនួន៥ នៅរាជធានីភ្នំពេញ ព្រមទាំងស្ថានភាពវិវត្តន៍បច្ចុប្បន្ននៃជំងឺកូវីដ-១៩ ក្នុងព្រះរាជាណាចក្រកម្ពុជា និងការរស់នៅក្នុងបរិបទថ្មី គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ សូមធ្វើការណែនាំ ដូចខាងក្រោម៖

1. ការព្យាបាល និងការធ្វើចត្តាឡីស័កក្រោយពេលព្យាបាល ចំពោះអ្នកជំងឺកូវីដ-១៩ ប្រភេទវិជ្ជមាន ត្រូវធ្វើដូចគ្នាទៅនឹងសេចក្តីកែសម្រួលលក្ខខណ្ឌក្នុងការបញ្ចប់ការព្យាបាលអ្នកជំងឺកូវីដ-១៩ សម្រាកព្យាបាលនៅផ្ទះ លក្ខខណ្ឌក្នុងការបញ្ចប់ការព្យាបាលអ្នកជំងឺកូវីដ-១៩ នៅមណ្ឌលព្យាបាលជំងឺកូវីដ-១៩ កម្រិតស្រាល និងលក្ខខណ្ឌក្នុងការបញ្ចប់ការព្យាបាលអ្នកជំងឺកូវីដ-១៩ កម្រិតមធ្យម និងធ្ងន់ នៅមន្ទីរពេទ្យព្យាបាលជំងឺកូវីដ-១៩ សម្រាប់អ្នកជំងឺកូវីដ-១៩ ប្រភេទអាល់ហ្វា ដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន (ដូចមានក្នុងឧបសម្ព័ន្ធជូនភ្ជាប់)។
2. អនុញ្ញាតឱ្យធ្វើការព្យាបាលអ្នកជំងឺកូវីដ-១៩ ប្រភេទវិជ្ជមាន នៅក្នុងមណ្ឌលព្យាបាលជំងឺកូវីដ-១៩ ឬមន្ទីរពេទ្យព្យាបាលជំងឺកូវីដ-១៩ ជាមួយគ្នានិងអ្នកជំងឺកូវីដ-១៩ ប្រភេទអាល់ហ្វា ដោយពុំចាំបាច់ធ្វើការញែកអ្នកជំងឺឡើយ។





@ឯកសារមន្ត្រីរាជការ_Telegram_

3. អនុញ្ញាតឱ្យវិស័យសុខាភិបាលឯកជនស្របច្បាប់ទទួលព្យាបាលអ្នកជំងឺកូវីដ-១៩ ប្រភេទស្រាលៗ។

4. អនុញ្ញាតឱ្យអ្នកជំងឺកូវីដ-១៩ ប្រភេទស្រាល ធ្វើការសម្រាកព្យាបាលនៅផ្ទះ ដោយមានការចូលរួមយ៉ាងសកម្មពីអាជ្ញាធរមូលដ្ឋាន និងពង្រឹងនូវការអនុវត្តវិធានការសុខាភិបាល និងវិធានការរដ្ឋបាល ឱ្យបានហ្មត់ចត់។

5. ចំពោះអ្នកជំងឺកូវីដ-១៩ ប្រភេទស្រាល ដែលកំពុងសម្រាកព្យាបាលនៅតាមមណ្ឌលព្យាបាលជំងឺកូវីដ-១៩ ឬមន្ទីរពេទ្យព្យាបាលជំងឺកូវីដ-១៩ លើសពីរយៈពេលកំណត់ក្នុងលក្ខខណ្ឌដែលបានចែង ត្រូវធ្វើតេស្ត PCR និងទទួលបានលទ្ធផលតេស្តអវិជ្ជមាន មុនអនុញ្ញាតឱ្យបញ្ចប់ការព្យាបាល។

លិខិតលេខ៣៧២សខល ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១ ស្តីពីលក្ខខណ្ឌនៃការបញ្ចប់ការព្យាបាលជំងឺកូវីដ-១៩ ប្រភេទស្រាល (បានបញ្ជាក់ដោយមន្ទីរពិសោធន៍ ឬស្ថិតក្នុងករណីសង្ស័យ) ត្រូវទុកជានិរាករណ៍។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវ ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពតាមការកិច្ចរៀងៗខ្លួន។

សូមឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

ម៉ម ប៊ុនហេង

**ចម្លងជូន៖**
- គណៈប្រចាំការនៃ គ.ប.ក.
- គណៈប្រតិបត្តិនៃ គ.អ.ក.
- គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ថ្នាក់រាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០

@ឯកសារមន្ត្រីរាជការ_Telegram_

# ឧបសម្ព័ន្ធ

## ១. លក្ខខណ្ឌក្នុងការបញ្ចប់ការព្យាបាលអ្នកជំងឺកូវីដ-១៩ កម្រិតស្រាល សម្រាកព្យាបាលនៅផ្ទះ




<u>កំណត់សំគាល់៖</u> ជាគោលការណ៍ ការសម្រាកថែទាំ និងព្យាបាលនៅផ្ទះ (រួមទាំងកាតព្វកិច្ចចត្តាឡីស័កបើមាន) មានរយៈពេលសរុប២៨ថ្ងៃ ដោយរាប់ចាប់តាំងពីថ្ងៃដឹងលទ្ធផលតេស្ត (+) ដំបូង (ថ្ងៃទី១ យកតាមទម្រង់មន្ទីរពិសោធន៍)។ ក្នុងករណីលទ្ធផលតេស្តនៅថ្ងៃទី១៣ PCR (-) រយៈពេលនៃការរង់ចាំលទ្ធផលតេស្ត PCR លើសពី ១ថ្ងៃ ត្រូវបានរាប់បញ្ចូលជារយៈពេលនៃការធ្វើចត្តាឡីស័ក ១៤ថ្ងៃ។


ទីស្ដីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ៨០ វិថីសម្ដេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០

## ២. លក្ខខណ្ឌក្នុងការបញ្ចប់ការព្យាបាលអ្នកជំងឺកូវីដ-១៩ នៅមណ្ឌលព្យាបាលជំងឺកូវីដ-១៩ កម្រិតស្រាល




<u>កំណត់សំគាល់៖</u>

ប្រសិនបើគ្មានរោគសញ្ញា ៣ថ្ងៃជាប់គ្នា ទោះបីជានៅតែរកឃើញ **PCR (+)** នៅថ្ងៃទី២១ កំអនុញ្ញាតឱ្យបញ្ចប់ការព្យាបាលដែរ (ដោយត្រូវបន្តចត្តាឡីស័ករយៈពេល ១៤ថ្ងៃនៅផ្ទះ) ។

## ៣. លក្ខខណ្ឌក្នុងការបញ្ចប់ការព្យាបាលអ្នកជំងឺកូវីដ-១៩ កម្រិតមធ្យម និងធ្ងន់ នៅមន្ទីរពេទ្យព្យាបាលជំងឺកូវីដ-១៩

